# ព្រឹត្តិបត្រព័ត៌មាន

គម្រោងពិពិធកម្មកសិកម្មកម្ពុជា

ឆ្នាំ២០២៣ - លេខ១



## មាតិកា

៣ ឯកឧត្តមរដ្ឋមន្ត្រី ឌិត ទីណា អញ្ជើញបើកការដ្ឋាន ...
៤ ឯកឧត្តមរដ្ឋមន្ត្រី ឌិត ទីណា អញ្ជើញចែកកូនស្វាយចន្ទី ...
៥ ការិយាល័យសម្របសម្រួលគម្រោងរៀបចំសិក្ខាសាលា...
៧ សិក្ខាសាលាប្រចាំឆ្នាំឆ្លុះបញ្ចាំងពីវឌ្ឍនភាព...
៨ មុខរបរដាំបន្លែក្នុងផ្ទះសំណាញ់...
៩ ឥណទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ៤0% ...
១០ សហគមន៍កសិកម្មស្ទឹងត្រង់សែនជ័យទទួលសំបុកឃ្មុំ ...
១១ សមាជិកសហគមន៍កសិកម្មព្រះរំកិល...
១២ វគ្គបណ្តុះបណ្តាលដល់សិក្ខាកាមចំនួន៣០ នាក់...
១៣ គម្រោងពិពិធកម្មកសិកម្មកម្ពុជារៀបចំទស្សនកិច្ចសិក្សា ...
១៤ អត្ថប្រយោជន៍នៃការប្រើប្រាស់ជញ្ជីងយន្ត...
១៥ មន្ត្រីបង្គោលចំនួន១៥ រូប មកពីមន្ទីរកសិកម្ម...
១៦ ម៉ាស៊ីនគោយន្តជួយកសិករសន្សំសំចៃពេលវេលា ...
១៧ អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា ...
១៨ ទុន៤0% ជួយសមាជិកសហគមន៍ព្រះរំកិល ...

### អំពីគម្រោង

គម្រោងមានគោលបំណងសំខាន់សម្របសម្រួលការអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃកសិកម្មនៅខេត្តគោលដៅដែលបានជ្រើសរើសនៅប្រទេសកម្ពុជា ។ គម្រោងមានសមាសភាគ៤ដូចខាងក្រោម៖

**សមាសភាគ១៖** បង្កើតពិពិធកម្មកសិកម្ម

**សមាសភាគ២៖** គាំទ្រហេដ្ឋារចនាសម្ព័ន្ធសាធារណៈ

**សមាសភាគ៣៖** កែលម្អប្រព័ន្ធព័ត៌មានកសិកម្ម និងគ្រប់គ្រងគុណភាព

**សមាសភាគ៤៖** គ្រប់គ្រងគម្រោង, សម្របសម្រួល, និងត្រួតពិនិត្យ និងវាយតម្លៃ



# សារនាយកគម្រោង

សូមគោរពជូនពរពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ! ខ្ញុំមានបីតិសោមនស្ស រីករាយបង្ហាញជូននូវព្រឹត្តិបត្រព័ត៌មានប្រចាំឆ្នាំរបស់គម្រោង CASDP។

យើងបន្តគាំទ្រកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើង និងស្តារឡើងវិញនៅក្នុងខេត្តគោលដៅចំនួន១៣ ដែលបានជ្រើសរើសដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយភ្នាក់ងារអនុវត្ត (I.A.) ទាំងអស់រួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) និងសហគមន៍កសិកម្ម និងដោយមានការគាំទ្រពីដៃគូរបស់យើងគឺធនាគារពិភពលោក។ រហូតមកដល់ពេលនេះ យើងបានដំណើរការអនុវត្តគម្រោងរយៈពេលជាងពាក់កណ្តាលអាណត្តិហើយ និងបានកំពុងធ្វើសកម្មភាពដ៏មមាញឹកគាំទ្រសហគមន៍កសិកម្មចំនួន១៩ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយគម្រោង CASDP ដើម្បីទទួលបានឥណទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ៤០%។ កិច្ចព្រមព្រៀងនេះបានអនុញ្ញាតិឱ្យសហគមន៍កសិកម្ម ចាប់ផ្តើមធ្វើសកម្មភាពប្រកបរបរអាជីវកម្មឡើងវិញ តាមរយៈការផ្តល់ធាតុចូលកសិកម្មសម្រាប់កែលម្អខ្សែច្រវ៉ាក់តម្លៃផលិតកម្មកសិកម្ម ដូចជាការចិញ្ចឹមសត្វ, សាកវប្បកម្ម, ជលផល និងកសិកម្ម ដូចជាជំឡូងមី, ស្វាយចន្ទី, ការចិញ្ចឹមឃ្មុំយកទឹក, ជីកសិកម្ម និងឧបករណ៍ពាក់ព័ន្ធកសិកម្មដទៃទៀត។

យើងបានបន្តធ្វើសកម្មភាពស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវលំជនបទតាមតម្រូវការជាក់ស្តែងរបស់សហគមន៍កសិកម្ម។ សមាសភាគនេះនឹងគាំទ្រដល់រាជរដ្ឋាភិបាល តាមរយៈការផ្តល់សេវាស្តារ និងកែលម្អផ្លូវដឹកជញ្ជូនផលកសិកម្មនៅជនបទ និងប្រព័ន្ធធារាសាស្ត្រធំៗ ដែលវិស័យកសិកធុរកិច្ចមិនមានលទ្ធភាពទទួលបាន ឬអាចប្រើប្រាស់បាន។ ស្របពេលជាមួយគ្នានេះដែរ យើងបានកំពុងធ្វើសកម្មភាពសំខាន់ៗមួយចំនួនដូចជា សកម្មភាពពង្រឹងធុរកិច្ចសហគមន៍ តាមរយៈការបណ្តុះបណ្តាលជំនាញ និងចែករំលែកចំណេះដឹងនវានុវត្តន៍លើការអភិវឌ្ឍន៍ផលិតផលកសិកម្ម អភិវឌ្ឍន៍តម្លៃបន្ថែម ការស្វែងរកទីផ្សារអាជីវកម្ម និងផែនការហិរញ្ញវត្ថុ។ សកម្មភាពទាំងនេះនឹងជួយធានាឱ្យសហគមន៍កសិកម្ម ទទួលបានផលប្រយោជន៍ពីប្រព័ន្ធលើកទឹកចិត្តឱ្យបន្តសកម្មភាពផលិតកម្មមិនមែនស្រូវ និងផលកសិកម្ម។ល។

ឆ្នាំនេះ ដោយមានការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យើងកំពុងដំណើរការជ្រើសរើសខេត្តសក្តានុពលចំនួន៤ បន្ថែមទៀត ដែលមានសហគមន៍កសិកម្មល្អ ដូចជា ខេត្តកំពង់ធំ ពោធិ៍សាត់ ប៉ៃលិន និងបន្ទាយមានជ័យ។ យើងទទួលស្គាល់ការជ្រើសរើសខេត្តទាំងនេះជាកិច្ចការសំខាន់សំដៅធានាបាននិរន្តរភាពនៃការអនុវត្តខ្សែច្រវ៉ាក់ផលិតកម្មកសិកម្ម និងជំរុញផលិតភាពកសិកម្មនៅមូលដ្ឋាន។

ដូចបានជំរាបជូនខាងលើនូវសកម្មភាពថ្មីៗបំផុតដែលយើងបានធ្វើជាមួយសហគមន៍កសិកម្ម និងក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គភាពអនុវត្តគម្រោង (I.A.s) ដើម្បីបង្កើនភាពធន់នឹងការគំរាមកំហែង ចំពោះវិស័យកសិកម្ម តាមរយៈការប្រើប្រាស់យន្តការទាំងអស់ដែលមានស្រាប់។ គម្រោងបានបណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រីបង្គោលនៃមន្ទីរកសិកម្ម ដែលបច្ចុប្បន្នសិក្ខាកាមទាំងនោះបានក្លាយជាធនធានសម្រាប់ការអនុវត្តកសិកម្មល្អ (CamGAP) និងការចិញ្ចឹមសត្វតាមបែបវិទ្យាសាស្ត្រ ការគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីលទ្ធកម្ម ដើម្បីជួយកសិករផ្សេងទៀតឱ្យអនុវត្តការងាររបស់ខ្លួនបានប្រសើរឡើងជាមុន។

ជាចុងក្រោយ យើងសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តសម្រាប់ការងារគម្រោង CASDP មិនថាតាមមធ្យោបាយណា ពោលគឺក្នុងគោលដៅរួមធ្វើឱ្យកសិកម្មរបស់ប្រទេសយើងមានការប្រែប្រួលជាវិជ្ជមាន។ ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី រីករាយក្នុងការអានព្រឹត្តិប័ត្រព័ត៌មានលេខនេះនូវសកម្មភាពមួយចំនួនរបស់គម្រោងក្នុងរយៈពេលមួយឆ្នាំកន្លងមក។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលអាន និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់មានសុវត្ថិភាព និងរីករាយក្នុងថ្ងៃឈប់វិស្សមកាលអន្តរជាតិ និងចាប់ផ្តើមការងារជាវិជ្ជមានសម្រាប់ឆ្នាំថ្មីខាងមុខ។

**លោកបណ្ឌិត សរ ចិត្រា**
អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
និងជានាយកគម្រោងពិពិធកម្មកសិកម្មកម្ពុជា

# ឯកឧត្តមរដ្ឋមន្ត្រី ឌិត ទីណា អញ្ជើញបើកការដ្ឋានជួសជុលកែលម្អផ្លូវចំនួន៤ខ្សែ ក្រោមគម្រោងពិពិធកម្មកសិកម្មកម្ពុជា

នៅព្រឹកថ្ងៃទី២០ ខែមិថុនាឆ្នាំ២០២៣ គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) បានរៀបចំពិធីបើក ការដ្ឋានជួសជុលកែលម្អផ្លូវចំនួន៤ខ្សែរក្រាលកៅស៊ូ និងគ្រួសក្រហមប្រវែងសរុប ២២,៥៣ គ.ម ស្ថិតក្នុងស្រុក ស្ទឹងត្រង់ ស្រុកព្រៃឈ ស្រុកជើងព្រៃ និងស្រុកបាធាយ ខេត្តកំពង់ចាម។ ផ្លូវទាំង៤ខ្សែនោះរួមមាន៖



- ផ្លូវសម្រាប់សហគមន៍កសិកម្មស្ទឹងត្រង់សែនជ័យ ស្ថិតនៅស្រុកស្ទឹងត្រង់ចំនួន២ខ្សែសរុប៧.០១គ.ម,
- ផ្លូវសម្រាប់សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង ស្ថិតនៅស្រុក ជើងព្រៃ និងស្រុក ព្រៃឈរ មានប្រវែង១០.០១គ.ម, និង
- ផ្លូវសម្រាប់សហគមន៍កសិកម្មអភិវឌ្ឍន៍មូលដ្ឋានយើងប្រវែង៥,៥១ គ.ម ស្ថិតនៅស្រុកបាធាយ។



Photo: MAFF 2023

ផ្លូវទាំង៤ខ្សែខាងលើស្ថិតនៅក្នុងចំណោមផ្លូវសរុបចំនួន២៥០ គ.ម ក្នុងខេត្តគោលដៅចំនួន១២ និង រាជធានីភ្នំពេញ ដែលគម្រោងពិពិធកម្មកសិកម្មកម្ពុជាគ្រោងជួសជុលកែលម្អ។ នៅក្នុងអង្គពិធីបើកការដ្ឋាន ប្រជាពលរដ្ឋបានសម្តែងសេចក្តីរីករាយ និងថ្លែងអំណរគុណចំពោះគម្រោងកែលម្អផ្លូវទាំង៤ខ្សែនេះថា មានសារសំខាន់ណាស់សម្រាប់ការដឹកជញ្ជូនផលកសិកម្មទៅកាន់ទីផ្សារ និងបម្រើឱ្យការធ្វើដំណើររបស់ប្រជាពលរដ្ឋ ទូទៅ ជាពិសេសប្រជាពលរដ្ឋក្នុងមូលដ្ឋាន រួមចំណែកលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងសហគមន៍ទាំងមូល។

# ឯកឧត្តមរដ្ឋមន្ត្រី ឌិត ទីណា អញ្ជើញចែកកូនស្វាយចន្ទី និងពូជស្រូវផ្ការំដួល ដល់សហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ នៅឃុំ រមទម ស្រុក រវៀង ខេត្ត ព្រះវិហារ


Photo: MAFF 2023

នៅរសៀលថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ ក្រោមកិច្ចសម្របសម្រួលរបស់គម្រោងពិពិធកម្មកសិកម្ម កម្ពុជា (CASDP) ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងថ្នាក់ដឹកនាំ បានអញ្ជើញសំណេះសំណាល និងចែកពូជស្វាយចន្ទី និងពូជស្រូវផ្ការំដួល ដល់សហគមន៍កសិកម្មរមទម សាមគ្គីមានជ័យ ស្ថិតនៅឃុំ រមទម ស្រុក រវៀង ខេត្ត ព្រះវិហារ។

នៅក្នុងអង្គពិធី ឯកឧត្តមរដ្ឋមន្ត្រី បានជម្រាបជូនសមាជិកសហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ ពីសក្តានុពលនៃការធ្វើកសិកម្មសរីរាង្គនៅខេត្តព្រះវិហារដែលជាខេត្តគោលដៅផលិតស្រូវសរីរាង្គមានតម្លៃទីផ្សារខ្ពស់ និងប្រកួតប្រជែងល្អ។

ឯកឧត្តមរដ្ឋមន្ត្រី បានមានប្រសាសន៍ថា ក្រសួងនឹងជួយសហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ ក្នុងការស្វែងរកទីផ្សារកាន់តែច្រើន តាមរយៈការពង្រឹងការធ្វើកសិកម្មតាមកិច្ចសន្យា និងការផ្តល់បច្ចេកទេសកសិកម្ម។ ឯកឧត្តមរដ្ឋមន្ត្រី បានណែនាំដល់ថ្នាក់ដឹកនាំ និងអ្នកពាក់ព័ន្ធឱ្យធ្វើផែនការច្បាស់លាស់ក្នុងការចិញ្ចឹម និងដាំដុះ ដើម្បីធានាការផ្គត់ផ្គង់តាមតម្រូវការទីផ្សារ ដោយធ្វើយ៉ាងណាចំណាយតិច បានចំណេញច្រើន។ មួយវិញទៀត គម្រោងគួរលើកផែនការសកម្មភាព និងថវិកាផ្អែកលើតម្រូវការរបស់កសិករ ក៏ដូចជាខេត្ត ដើម្បីអនុវត្តត្រូវតាមគោលការណ៍។ ទន្ទឹមនឹងនេះ ក៏ត្រូវពិនិត្យលទ្ធភាពគ្រប់គ្រង និងប្រើប្រាស់ទឹកឱ្យមានប្រសិទ្ធភាពសម្រាប់វិស័យកសិកម្ម។ បន្ថែមលើនេះទៀត ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍កសិកម្ម និងកំណត់ទីផ្សារច្បាស់លាស់ជូនកសិករ ហើយសម្រាប់ខេត្តនេះដែរ ឯកឧត្តម រដ្ឋមន្ត្រីបានស្នើឱ្យឯកឧត្តមរដ្ឋលេខាធិការ ទទួលបន្ទុកជួយបងប្អូនលើការងារបច្ចេកទេស និងបញ្ហាផ្សេងៗ សំដៅធ្វើយ៉ាងណាឱ្យការកែទម្រង់កសិកម្ម មានប្រសិទ្ធភាព៕

# ការិយាល័យសម្របសម្រួលគម្រោង រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអនុវត្តផែនការពិពិធកម្មកសិកម្ម (DPLs) និងផែនការធុរកិច្ច (BPLs) និងជំនួយបច្ចេកទេសសម្រាប់ការអនុវត្តជំនួយបំពេញបន្ថែមទុនវិនិយោគ





*Photo: MAFF 2023*

គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) បានទទួលសំណើពិពិធកម្មកសិកម្មចំនួន៦៣ ពីសហគមន៍ កសិកម្ម (A.C.s) ក្នុងនោះ១៩ សហគមន៍កសិកម្ម បានទទួលជោគជ័យសម្រាប់សំណើឥណទាន៤០% នៃទុនវិនិយោគសរុបពីគម្រោង។ ក្រោយពីចុះហត្ថលេខារួច សហគមន៍កសិកម្មបានដំណើរការអនុវត្តសកម្មភាពពិពិធ កម្មកសិកម្ម និងផែនការធុរកិច្ច ដោយអនុលោមតាមនីតិវិធីនានារបស់គម្រោង ដែលសហគមន៍កសិកម្មភាគច្រើនមិនបានយល់ដឹង។

ក្នុងពេលអនុវត្ត សហគមន៍កសិកម្មបានជួបបញ្ហាប្រឈមមួយចំនួនដូចជា ចំណេះដឹង និងសមត្ថភាព នៅមានកម្រិតក្នុងការរៀបចំឯកសារដេញថ្លៃឱ្យស្របតាមលក្ខណៈបច្ចេកទេស និងប្លង់គំរូ និងបញ្ជីប៉ាន់ស្មានតម្លៃ (BoQ) សម្រាប់ការងារសំណង់។ ការស្វែងរកអ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការដែលបានចុះបញ្ជី ឬមានបណ្ណប៉ាតង់ត្រឹមត្រូវនៅកម្រិតសហគមន៍ នៅតែជាបញ្ហាប្រឈមសម្រាប់សហគមន៍មុនពេលទទួលបានធាតុចូលកសិកម្ម។

ការិយាល័យសម្របសម្រួលគម្រោង (PCO) សហការជាមួយក្រុមការងារធនាគារពិភពលោកទទួលបន្ទុកគម្រោង CASDP បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពស្តីពី “ការអនុវត្តផែនការពិពិធកម្ម និងធុរកិច្ច ជំនួយបច្ចេកទេសសម្រាប់ការអនុវត្តឥតសំណងបំពេញបន្ថែមទុនវិនិយោគ” ឱ្យបានត្រឹមត្រូវ ដើម្បីបង្កើនការយល់ដឹង, សមត្ថភាព, ចំណេះដឹង, និងបទពិសោធន៍បន្ថែមទាក់ទងនឹងកិច្ចគាំពារសង្គម និងបរិស្ថាន, ហិរញ្ញវត្ថុ, កិច្ចលទ្ធកម្ម, និងឥណទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពាក់ព័ន្ធផ្សេងទៀត។ សិក្ខាកាមចំនួន៧៣ នាក់ មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងសហគមន៍កសិកម្ម, អ្នកផ្តល់សេវា, និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលចូលរួមអនុវត្តគម្រោង (PDAFF, A.C.s, TSP និង PFI) បានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០២៣ នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

វាគ្មិនកិត្តិយសដែលបានអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលា ឯកឧត្តម **យ៉ង សាំងកុមារ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងជាអនុប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម (CARDI), ឯកឧត្តមបណ្ឌិត **ហ៊ាន វណ្ណាហាន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មការតម្រង់ទិសគម្រោង CASDP, លោកជំទាវ ចំរើន មុទិតា ប្រធានក្រុមការងារធនាគារពិភពលោកប្រចាំកម្ពុជាទទួលបន្ទុកគម្រោង CASDP លោកបណ្ឌិត **សរ ចិត្រា** អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជានាយកគម្រោង CASDP និងទីប្រឹក្សាគម្រោង CASDP បានពិភាក្សាពីកិច្ចគាំពារសង្គម និងបរិស្ថាន, ហិរញ្ញវត្ថុ, កិច្ចលទ្ធកម្ម, និងបន្ទាត់ឥណទាន។ សិក្ខាសាលារយៈពេលពីរថ្ងៃបានប្រព្រឹត្តិទៅដោយរលូន មានការពិភាក្សាយ៉ាងផុសផុល និងទទួលបានផ្លែផ្កាល្អ។

វាគ្មិនក៏បានធ្វើបទបង្ហាញពីវិធីសាស្ត្រពង្រឹងសមត្ថភាពបច្ចេកទេស ដល់មន្ត្រីបង្គោលនៃមន្ទីរក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និងនេសាទ (PDAFF) ដើម្បីចូលរួមគាំទ្រដល់ដំណើរការអនុវត្តកិច្ចព្រមព្រៀងជំនួយឥតសំណងបំពេញបន្ថែមទុនវិនិយោគជាមួយក្រុមការងារគម្រោង CSADP និងសហគមន៍កសិកម្មពាក់ព័ន្ធជាមួយផែនការពិពិធកម្ម និងផែនការធុរកិច្ចដែលបានអនុម័តរួច។ ក្នុងបទបង្ហាញក៏បានលើកឡើងពីតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមកពីសហគមន៍កសិកម្ម, មន្ទីរកសិកម្ម, អ្នកផ្តល់សេវាគាំទ្រ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, អង្គភាពអនុវត្តគម្រោងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលចូលរួមអនុវត្តគម្រោង(AC, PDAFF, TSSP) MAFF, MEF-PIU/PFIs) ដើម្បីពន្លឿនសកម្មភាពអនុវត្តសកម្មភាពពិពិធកម្មកសិកម្មឱ្យបានទាន់ពេលវេលា។

អង្គសិក្ខាសាលាបានលើកទឹកចិត្តឱ្យអ្នកចូលរួមទាំងអស់ ពិភាក្សាឱ្យបានគ្រប់ជ្រុងជ្រោយ ដោយអ្នកសម្រប សម្រួល និងក្រុមការងារគ្រប់គ្រងគម្រោង CASDP បានលើកយកប្រធានបទសំខាន់ៗមកពិភាក្សាក្នុងវគ្គបណ្តុះបណ្តាល សំដៅដោះស្រាយបញ្ហាប្រឈមនានា ដែលសមាជិក A.C. និងមន្ត្រី PDAFF បានជួបប្រទះក្នុងពេលអនុវត្ត។ បទបង្ហាញផ្តោតសំខាន់លើការអនុវត្តកិច្ចព្រមព្រៀងឥណទានឥតសំណងបន្ថែមទុនវិនិយោគ និងពិនិត្យលើផែនការពិពិធកម្មកសិកម្ម និងធុរកិច្ច (DPL/BPL) គាំទ្រដោយ AEC ដើម្បីត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទាន (MGA) ផ្តោតលើបញ្ហាប្រឈម និងដំណោះស្រាយ, នីតិវិធីផ្តល់សេវាឥណទាន បញ្ហាប្រឈម និងដំណោះស្រាយ, តួនាទី និងទំនួលខុសត្រូវអនុវត្ត DPL (A.C, PDAFF, TSPs, PCO/MAFF, MEF-PIU/PFI), ការគ្រប់គ្រងទិន្នន័យ និងរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ, នីតិវិធីលទ្ធកម្មសហគមន៍កសិកម្មដូចជាកិច្ចសន្យាទំនិញ និងការងារសាងសង់, នីតិវិធីទូទាត់សំណង និងកិច្ចគាំពារបរិស្ថាន និងសង្គមដែលត្រូវអនុវត្តនៅក្នុង DPLs ។

ជាលទ្ធផល អ្នកចូលរួមបានបង្ហាញចំណាប់អារម្មណ៍ និងកោតសរសើរចំពោះរបៀបវារៈនៃកិច្ចពិភាក្សាថា បានលើកឡើងចំៗលើបញ្ហាប្រឈម ដែលពួកគេកំពុងជួបប្រទះក្នុងការអនុវត្តផែនការធុរកិច្ចប្រចាំថ្ងៃរបស់ពួកគេ។ បញ្ហាខ្វះចន្លោះត្រូវបានរកឃើញក្នុងអំឡុងពេលធ្វើបទបង្ហាញ ហើយអ្នកចូលរួមបានទទួលស្គាល់ថា ផ្នែកខ្លះបានអនុវត្តមិនទាន់សមស្របតាមនីតិវិធីនៅឡើយ។ ជារួម វគ្គបណ្តុះបណ្តាលទទួលបានជោគជ័យ ព្រោះកម្មវិធីបានរៀបចំឡើងស្របតាមតម្រូវការចាំបាច់សម្រាប់ការអនុវត្តគម្រោង។ លើសពីនេះ អ្នកចូលរួមបានបង្កើនជំនាញបន្ថែម ជាពិសេសជំនាញគ្រប់គ្រងឥណទាន, គ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីលទ្ធកម្ម ដែលអាចយកទៅប្រើប្រាស់ និងកែ





*Photo: MAFF 2023*

លម្អការអនុវត្តទូទៅឱ្យសម្រេចបានលទ្ធផលល្អ។ ម្យ៉ាងវិញទៀត អ្នកចូលរួមបានយល់ដឹងពីទស្សនទាននៃទុនវិនិយោគបំពេញបន្ថែម ការទូទាត់ និងការផ្តល់សំណងតបតាមការចង់បានរបស់ភាគីពាក់ព័ន្ធ។

ផ្អែកលើសមិទ្ធកម្មដែលបានរកឃើញក្នុងវគ្គបណ្តុះបណ្តាលនេះបានឱ្យដឹងថា នៅពេលខាងមុខ សកម្មភាពស្រដៀងគ្នានេះគួរត្រូវបានរៀបចំបន្ថែម ជាពិសេស វគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យ និងវាយតម្លៃ គម្រោង

ដើម្បីឱ្យសិក្ខាកាមជាថ្នាក់ដឹកនាំយកទៅអនុវត្ត។ សិក្ខាសាលាបានផ្ដល់អនុសាសន៍ឱ្យធ្វើការវិភាគពីចំនុចខ្វះខាតផ្នែកជំនាញឱ្យបានច្បាស់មុនពេលរៀបចំបណ្ដុះបណ្ដាល ដោយចងក្រងពីសាវតាសមត្ថភាពសិក្ខាកាមដែលបានកំពុងទទួលខុសអនុវត្តគម្រោង។

ក្រោយបញ្ចប់វគ្គបណ្ដុះបណ្ដាល អ្នកចូលរួមបានយល់ដឹងកាន់តែច្បាស់ពីការងារអនុវត្តគម្រោងការងារ លទ្ធកម្ម គោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុ និងដំណើការអនុវត្ត និងគ្រប់គ្រងគម្រោងទទួលបានជោគជ័យ។ ជាមួយគ្នានេះដែរ អ្នកចូលរួមទទួលបានជំនាញគ្រប់គ្រងគម្រោងគម្រោង និងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីមាន សមត្ថភាពសម្របសម្រួល និងគ្រប់គ្រងសកម្មភាពគម្រោងនៅតាមសហគមន៍កសិកម្មប្រកបដោយតម្លាភាព មានប្រសិទ្ធភាព និងប្រសិទ្ធផល។



Photo: MAFF 2023

## សិក្ខាសាលាប្រចាំឆ្នាំឆ្លុះបញ្ចាំងពីវឌ្ឍនភាពការអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP)

សិក្ខាសាលាប្រចាំឆ្នាំឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) ត្រូវបានរៀបចំឡើងនៅសណ្ឋាគារ សុខាល័យអង្គរ ខេត្តសៀមរាប នៅថ្ងៃទី១១-១២ ខែមករា ឆ្នាំ២០២៣ ដើម្បីពិនិត្យលើសមិទ្ធផលនានា និងបញ្ហាប្រឈម ដែលបានអនុវត្តកាលពីឆ្នាំ២០២២ និងកំណត់ចងក្រងបទពិសោធន៍សំខាន់ៗសម្រាប់កែលម្អការអនុវត្តគម្រោងឱ្យបានល្អប្រសើរនៅឆ្នាំ២០២៣។

អង្គសិក្ខាសាលាបានប្រព្រឹត្តិទៅរយៈពេល២ថ្ងៃ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **យ៉ង សាំងកុមារ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានក្រុមប្រឹក្សាស្ដារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តមបណ្ឌិត **ហ៊ាន វណ្ណហាន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង



Photo: MAFF 2023

ជាប្រធានគណៈកម្មការតម្រង់ទិសអនុវត្តគម្រោង (PSC) និង លោកស្រី **ចំរើន មុទិតា** អ្នកឯកទេសជាន់ខ្ពស់អភិវឌ្ឍន៍ជនបទ និងជាប្រធានគម្រោង CASDP នៃធនាគារពិភពលោក។ ឯកឧត្តម ឃី កុសល អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាសមាជិកគណៈកម្មការតម្រង់ទិសគម្រោង (PSC) ឯកឧត្តម សាន វិសាល តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោកបណ្ឌិត **សរ ចិត្រា** អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជានាយកគម្រោង CASDP ក៏បានអញ្ជើញចូលរួមអង្គសិក្ខាសាលានោះដែរ ។

អ្នកចូលរួមចំនួន១០៩នាក់ តំណាងមកពីស្ថាប័នអនុវត្តគម្រោង (IAs) មាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ដៃគូរអនុវត្តមានធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍ជនបទ (ARDB) អ្នកផ្តល់សេវាបច្ចេកទេស (TSPs) តំណាងមកពីស្ថាប័នហិរញ្ញវត្ថុចូលរួមអនុវត្តគម្រោងរួមមាន ធនាគារប្រៃសណីយ៍កម្ពុជា ធនាគារ AMK និង ធនាគារចំរើន សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) វិទ្យាស្ថានជាតិកសិកម្មព្រែកលាប វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម សហគ្រាសកសិធុរកិច្ចខ្នាតតូច និងមធ្យម រួមមានក្រុមហ៊ុន Tropicam សម្រាប់ផលិតកម្មបន្លែសុវត្ថិភាព និងក្រុមហ៊ុន SANTANA Agro Product., Ltd. សម្រាប់គ្រាប់ស្វាយចន្ទី សមាជិកនៃគណៈកម្មការក្រុមប្រឹក្សាពិគ្រោះយោបល់ និងអនុម័ត (AEC&EC) និងតំណាងមកពីសហគមន៍កសិកម្មតាសីសាមគ្គី ។



Photo: MAFF 2023

## មុខរបរដាំបន្លែក្នុងផ្ទះសំណាញ់ បានជួយឱ្យអ្នកស្រី ឡាយ សេងហឿន បញ្ជូនកូនទៅរៀននៅសាលាពេទ្យ

អ្នកស្រី ឡាយ សេងហឿន ជាកសិករនៅជនបទ ឃុំ ពេជ្រចិន្តា ស្រុក ភ្នំព្រឹក ខេត្ត បាត់ដំបង ជាកន្លែងដែលអ្នកស្រី និងស្វាមីធ្លាប់ដាំពោត ដំឡូងមី និងបន្លែផ្លែឈើផ្សេងៗ។ គ្រួសាររបស់អ្នកស្រីធ្លាប់ប្រកបរបរ កសិកម្មតូចតាច និងអាចរកប្រាក់ចំណូលបានមកពីការលក់ផលិតផលកសិកម្មមួយចំនួននៅក្នុងសហគមន៍។

តែដោយសារការបម្រែបម្រួលអាកាសធាតុ និងការធ្លាក់ចុះទិន្នផលកសិកម្ម បានធ្វើឱ្យមុខរបររបស់អ្នក ស្រីជួបការលំបាក។ ទោះជាយ៉ាងនេះក្តី ដោយសារមានការគាំទ្រពីគម្រោង CASDP នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់



_អ្នកស្រី ឡាយ សេងហឿង ( ពាក់មួក ) កំពុងប្រមូលផលបន្លែនៅក្នុងផ្ទះសំណាញ់. Photo: MAFF/2023

និងនេសាទ សហការជាមួយធនាគារពិភពលោក បានធ្វើឱ្យសហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា និង កសិដ្ឋានរបស់លោកស្រី ឡាយ សេងហឿន បានឈរយ៉ាងរឹងមាំក្នុងមុខរបរ។

គម្រោងបានផ្តល់ហិរញ្ញប្បទានឥតសំណង៤០% ដើម្បីសាងសង់ផ្ទះសំណាញ់ និងប្រព័ន្ធស្រោចស្រព ផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមពី បច្ចេកទេសរក្សាដីឱ្យមានជីជាតិសម្រាប់ដាំបន្លែផ្សេងៗនៅក្នុងផ្ទះសំណាញ់ចំនួន១២ខ្នងទទួលបានពីគម្រោង។ ឥឡូវនេះអ្នកស្រីអាចប្រមូលផលបានច្រើនជាង៧២,០០០ គ.ក ក្នុង១ខែ

ដែលជាដំណាំវិលជុំ។

ការដាំដុះដំណាំ និងបន្លែវិលជុំ ជាដំណោះស្រាយដ៏ល្អមួយ ដើម្បីបញ្ចៀសការកកស្ទះនៅតាមទីផ្សារ និងទទួលបានប្រាក់ចំណូលសមរម្យសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់អ្នកស្រីផងដែរ។ ជាមួយនឹងប្រាក់ចំណូលពី ការលក់បន្លែ អ្នកស្រីអាចមានលទ្ធភាពផ្គត់ផ្គង់គ្រួសារ និងសម្រាប់ការសិក្សារបស់កូនអ្នស្រី ដែលនាងកំពុងបន្ត ការសិក្សាថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។

## ឥណទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ៤០% បានផ្តល់ឱកាសឱ្យលោក លី លាងគី បង្កើនផ្ទះសំណាញ់ដាំបន្លែសុវត្ថិភាពពី២ខ្នងទៅ៣០ ខ្នង

លោក លី លាងគី ជាសមាជិកក្រុមផលិតមកពីសហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា និងជាកសិករនៅភូមិ រកាបុស្ស ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង បានឱ្យដឹងថា លោកបានដាំបន្លែសុវត្ថិភាព មានរយៈពេល៣ឆ្នាំមកហើយ ដោយចាប់ផ្តើមពីផ្ទះសំណាញ់តែ១ខ្នងប៉ុណ្ណោះ ដែលគាត់អាចរកបាន១ លានរៀល ក្នុង១វដ្តប្រមូលផល។ ជាមួយការគាំទ្រពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា គាត់មានលទ្ធភាពពង្រីកការដាំដុះបន្ថែមរហូតដល់គាត់មានផ្ទះសំណាញ់ចំនួន៣០ ខ្នង នៅលើផ្ទៃដី១ ហិកតា។ មុនពេលទទួលបានការគាំទ្រពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា ( CASDP ) កសិករក្រុមផលិតបានដាំបន្លែនៅក្រៅផ្ទះសំណាញ់ចំណាយច្រើនទៅលើជីកសិកម្ម បញ្ហាសត្វបំផ្លាញ និងទិន្នផលធ្លាក់ចុះជាបន្តបន្ទាប់។ កសិករ និងកសិដ្ឋានភាគច្រើនបានងាកមកដាំបន្លែសុវត្ថិភាពនៅក្នុងផ្ទះសំណាញ់វិញ ដើម្បីផលិតបាន៣ដងក្នុង១ឆ្នាំ។

លោកបន្តថា គម្រោង CASDP របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយធនាគារពិភពលោក បានផ្តល់ឱកាសឱ្យលោកមានផ្ទះសំណាញ់សម្រាប់ដាំបន្លែសុវត្ថិភាព និងអនុញ្ញាតឱ្យលោកអាចដាំដំណាំវិលជុំពេញ១ឆ្នាំ

ដែលនេះជាអត្ថប្រយោជន៍ចំពោះផ្ទះសំណាញ់ ព្រោះការដាំបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់មានភាពខុសគ្នាឆ្ងាយពីការដាំបន្លែលក្ខណៈគ្រួសារសាមញ្ញៗ និងបានប្រើបច្ចេកទេសផ្សេងៗ ដូចជាការប្រើថ្នាំសម្លាប់សត្វល្អិតនៅមានកម្រិតតិចតួច។

លោកបានបន្តថា “នៅពេលយើងដាំបន្លែជាលក្ខណៈគ្រួសារ យើងមិនអាចជៀសផុតពីការប្រើថ្នាំសម្លាប់សត្វល្អិតបានទេ។ ប៉ុន្តែនៅពេលយើងដាំនៅក្នុងផ្ទះសំណាញ់ សត្វល្អិតមិនហ៊ានវាយប្រហារបន្លែយើងទេ ដូច្នេះយើងមិនចាំបាច់ប្រើវាញឹកញាប់ពេកដែរ” ។



*Photo: MAFF 2023*

## សហគមន៍កសិកម្មស្ទឹងត្រង់សែនជ័យទទួលសំបុកឃ្មុំ និងពូជឃ្មុំពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា



លោក លួង តាក់, ប្រធានសហគមន៍ស្ទឹងត្រង់សែនជ័យ(អាវយឺតលឿង) ក្នុងពិធីចែកកូនឃ្មុំ និងសំបុកឃ្មុំ. Photo: MAFF/2023

ឃ្មុំមានតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអេកូឡូស៊ីត្រូពិច ប៉ុន្តែការប្រមូលផលទឹកឃ្មុំដែលមិនបានគិតពីនិរន្តរភាពអាចធ្វើឱ្យប្រជាសហគមន៍អ្នកទទួលផលនៅក្នុងតំបន់រងផលប៉ះពាល់ទៅវិញ។ បច្ចុប្បន្ន ឃ្មុំកំពុង “បាត់បង់” ជាបណ្តើរៗ ដោយសារប្រព័ន្ធអេកូឡូស៊ីចម្រុះធ្លាក់ចុះ ហើយការប្រមូលផលទឹកឃ្មុំទៀតសោត បានអនុវត្តតាមបែបប្រពៃណី ដែលជាដើមចមនាំឱ្យមានការបំផ្លិចបំផ្លាញដល់ហ្វូងឃ្មុំទាំងមូល។

ទោះបីជាមានការធ្លាក់ចុះនូវបរិមាណឃ្មុំក៏ដោយ ប៉ុន្តែឃ្មុំនៅតែមានសក្តានុពលនៅលើទីផ្សារអន្តរជាតិ សម្រាប់ទឹកឃ្មុំកម្ពុជា តែវាក៏ត្រូវការរយៈពេលពី៥ ទៅ១០ ឆ្នាំ ដើម្បីចិញ្ចឹមវាបាន។ ក្នុងភាពជាដៃគូជាមួយ ធនាគារពិភពលោក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បានចាប់ផ្តើមអនុវត្តគម្រោងឃ្មុំ តាមរយៈ គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) ដោយផ្តល់ជំនួយឥតសំណងបំពេញបន្ថែមទុនវិនិយោគ៤០% សម្រាប់ការកែលម្អប្រព័ន្ធខ្សែសង្វាក់តម្លៃផលិតកម្មឃ្មុំឱ្យកាន់តែប្រសើរឡើង ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ មន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF) ខេត្តកំពង់ចាម បានចែកសំបុកឃ្មុំ និងពូជឃ្មុំ ដល់សហគមន៍កសិកម្មស្ទឹងត្រង់សែនជ័យ ឃុំ សុភាស ស្រុក ស្ទឹងត្រង់ ខេត្តកំពង់ចាម។ ក្រៅពីទទួលបានពូជឃ្មុំ កសិករចិញ្ចឹមឃ្មុំក៏នឹងទទួលបានការណែនាំ និងការបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមឃ្មុំ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវដឹកជញ្ជូនផលកសិកម្មផងដែរ។

គម្រោងចិញ្ចឹមឃ្មុំជាផែនការធុរកិច្ចមួយក្នុងចំណោមផែនការផ្សេងទៀត គាំទ្រដោយគម្រោង CASDP បានដើរតួនាទីសំខាន់គាំទ្រនិរន្តរភាពវិស័យកសិកម្ម ហើយការចិញ្ចឹមឃ្មុំក៏បានបង្កើតការងារសម្រាប់សហគមន៍ និងមានសមាជិកចំនួន១៧១ នាក់ ក្នុងនោះស្ត្រី៧១នាក់ ជាអ្នកទទួលផលពីគម្រោងចិញ្ចឹមឃ្មុំ។

# សមាជិកសហគមន៍កសិកម្មព្រះរំកិលចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ





_ អ្នកជំនាញបសុសត្វ, ជាមន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងពន្យល់សមាជិកសហគមន៍កសិកម្មព្រះរំកិល, ខែធ្នូ ២០២៣. Photo: MAFF/2023

បច្ចុប្បន្ន កសិករភាគច្រើននៅភូមិក្រឡាពាស ឃុំ ព្រះរំកិល ស្រុក បូរីអូស្វាយសែនជ័យ ខេត្ត ស្ទឹងត្រែង នៅប្រកបរបរចិញ្ចឹមជ្រូកតាមប្រពៃណីនៅឡើយ ខណៈដែលពួកគេពុំដឹងថាគួរចិញ្ចឹមជ្រូករបៀបណាដើម្បីឱ្យ បានផលល្អ។

វិធីការពារជំងឺឆ្លងលើសត្វជ្រូក ការថែទាំដោយបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមសត្វជ្រូក និងដាក់បង្ខាំងសត្វជ្រូកដាច់ដោយឡែក, ការជ្រើសរើសពូជកូនជ្រូកដែលល្អមកចិញ្ចឹម ជាចំណេះដឹងដែលកសិករគ្រប់រូបត្រូវយល់ដឹងមុនគេមុនពេលសម្រេចចិត្តចិញ្ចឹមជ្រូក។

គម្រោងពិពិធកម្មកសិកម្មកម្ពុជា ក្រោមកិច្ចសម្របសម្រួលពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (GDAHP) បានបើកវគ្គបណ្តុះបណ្តាលសម្រាប់សមាជិកសហគមន៍កសិកម្មព្រះរំកិលស្តីពី ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ ស្របតាមគោលការអង្គការពិភពលោកសម្រាប់សុខភាពសត្វ។ វគ្គបណ្តុះបណ្តាលបានផ្តោតលើការរៀបចំទ្រុង និងសម្ភារៈក្នុងទ្រុងជ្រូក, ការជ្រើសរើសពូជ និងការបង្កាត់ពូជជ្រូក, ការរៀបចំចំណី និងការផ្តល់ចំណីជ្រូក, អនាម័យ ជីវៈសុវត្ថិភាព និងការការពារជម្ងឺជ្រូកកាលពីថ្ងៃទី២១-២២ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្នាក់ការសហគមន៍កសិកម្មព្រះរំកិល។

ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាលរួចមក កសិករចិញ្ចឹមជ្រូកប្រហែល៧៥ នាក់ បានទទួលចំណេះដឹងស្តីពីការជ្រើសរើសពូជជ្រូក, ការសង់ទ្រុងជ្រូក, ការផ្តល់ចំណីនឹងទឹក, ការថែទាំមេជ្រូក និងកូន, ការថែទាំជ្រូកជំទង់ និងជ្រូកសាច់, ការធ្វើអនាម័យ និងវិធានការការពារសុខភាពសត្វ, យល់ដឹងពីជំងឺដែលច្រើនកើតនៅលើជ្រូក និងមេជ្រូក។ អ្នកចូលរួមបានសំដែងនូវសេចក្តីសប្បាយរីករាយ និងថ្លែងអំណរគុណដល់គម្រោងដែលបានផ្តួចផ្តើមឱ្យមានវគ្គបណ្តុះបណ្តាលនេះឡើង និងបានប្តេជ្ញាយកចំណេះដឹងទាំងនេះយកទៅអនុវត្តឱ្យទទួលបានជោគជ័យ។

# វគ្គបណ្តុះបណ្តាលដល់សិក្ខាកាមចំនួន ៣០នាក់ មកពីសហគមន៍កសិកម្មសាមគ្គីអមលាំងស្តីពីស្តង់ដារការអនុវត្តកសិកម្មល្អកម្ពុជា CamGAP





_លោក ហេង ឈុនហ៊ី, អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( GDA/MAFF ). Photo: MAFF/2023

ដោយសារមានតម្រូវការកើនឡើងនូវផលិតផលម្ហូបអាហារដែលមានគុណភាពខ្ពស់ និងសុវត្ថិភាព ជាងមុន សម្រាប់អ្នកប្រើប្រាស់ បានក្លាយជាបញ្ហាទូទៅសម្រាប់ទាំងប្រទេសនាំចូល និងអ្នកប្រើប្រាស់ក្នុងស្រុក ដែលតម្រូវឱ្យមានវិញ្ញាបនប័ត្រទទួលស្គាល់ពីការអនុវត្តកសិកម្មល្អ CamGAP ក្នុងការផលិត និងចែកចាយអាហារ។ អ្នកពាក់ព័ន្ធក្នុងវិស័យកសិកម្មកម្ពុជាបានទទួលស្គាល់ថា CamGAP ពិតជាមានភាពចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងសកម្មភាពកសិកម្មទាំងអស់ឱ្យបានទូលំទូលាយជាងមុន ដើម្បីឈានទៅប្រកួតប្រជែងជាមួយប្រទេសអាស៊ានដទៃទៀត និងទទួលបានអត្ថប្រយោជន៍ពីការចូលទៅកាន់ទីផ្សារក្នុងតំបន់កាន់តែធំ។

ការអភិវឌ្ឍន៍ និងការអនុវត្តវិធានការ GAP CamGAP របស់កម្ពុជានឹងបង្កើតជាធាតុចូលបន្ថែមទៀតគួរឱ្យទុកចិត្តលើគុណភាព បង្កើនតម្លៃកសិកម្ម និងអភិវឌ្ឍជំនាញរបស់កសិករ។ ក្នុងបរិការនេះអាចជាបញ្ហា ប្រឈមដែលប្រទេសកម្ពុជាកំពុងជួបប្រទះ ដូច្នេះគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) ក្រោមហិរញ្ញប្បទានពីធនាគារពិភពលោក បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី “ស្តង់ដារការអនុវត្តកសិកម្មល្អ” នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ នៅសហគមន៍កសិកម្មសាមគ្គីអមលាំង ខេត្ត កំពង់ស្ពឺ។

លោក ហេង ឈុនហ៊ី អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( GDA/MAFF ) បានធ្វើជាវាគ្មិនក្នុងកម្មវិធីបណ្តុះបណ្តាលដល់សិក្ខាកាមចូលរួមពី ALAC ចំនួន៣០ នាក់។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងបង្កើនចំណេះដឹង និងសមត្ថភាព សំដៅលើកកម្ពស់ការយល់ដឹងកាន់តែប្រសើរស្តីពី ស្តង់ដារការអនុវត្តកសិកម្មល្អ ដល់សមាជិកសហគមន៍កសិកម្ម និងនីតិវិធីចុះបញ្ជីដីកសិកម្ម។ វគ្គបណ្តុះបណ្តាលនេះនឹងបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យកសិកម្ម និងការទទួលបានឱកាសទីផ្សារសម្រាប់ក្រុមផលិត។

ជាលទ្ធផល សមាជិកសហគមន៍កសិកម្មមានសមត្ថភាពចែករំលែកចំណេះដឹង និងជួយផ្សព្វផ្សាយ ពីគោលការណ៍អនុវត្តកសិកម្មល្អកាន់តែទូលំទូលាយទៅដល់កសិករដទៃៗទៀត ដែលបាននឹងកំពុងដាំដុះតាមទម្លាប់ ហើយងាកមកអនុវត្តតាមគោលការ CamGAP សំដៅផ្គត់ផ្គង់បន្លែ និងផ្លែឈើស្រស់កម្ពុជាចូលទៅកាន់ទីផ្សារក្នុងស្រុក និងនាំចេញឱ្យបានច្រើន និងជឿទុកចិត្ត។

# គម្រោងពិពិធកម្មកសិកម្មកម្ពុជារៀបចំទស្សនកិច្ចសិក្សាដកបទពិសោធន៍ទៅកាន់សហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា ខេត្ត បាត់ដំបង




_លោក ហ៊ុន វុត្ថា, ប្រធានសហគមន៍ពន្លឺថ្មីពេជ្រចិន្តា (ឆ្វេង) កំពុងពន្យល់អ្នកទស្សនាសួនបន្លែ, ខែធ្នូ ២០២៣. Photo: MAFF/2023

គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) សហការជាមួយនាយកដ្ឋានសហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម បានរៀបចំទស្សនកិច្ចសិក្សានៅកាន់សហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា ស្រុក ភ្នំព្រឹក ខេត្តបាត់ដំបង នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣។

ដំណើរទស្សនកិច្ចនេះ ជាសកម្មភាពមួយក្នុងចំណោមសកម្មភាពជាច្រើនតាមតំបន់គោលដៅរបស់ គម្រោង CASDP ក្នុងគោលបំណងគាំទ្រដល់ការប្រមូលជាតុចូល ការផ្សព្វផ្សាយព័ត៌មានបច្ចេកទេស ការបង្កើត ទីផ្សារ និងការអនុវត្តបទប្បញ្ញត្តិស្តីពីការអនុវត្តកសិកម្មល្អ (GAPs) ។

ក្រុមអ្នកផលិតផលិតផលកសិកម្មកម្ពុជាភាគច្រើន ជាពិសេសកសិករខ្នាតតូច និងមធ្យម ត្រូវការចំណេះដឹង និងជំនាញបន្ថែម និងលទ្ធភាពទទួលបានជាតុចូលប្រកបដោយភាពច្នៃប្រឌិត និងបច្ចេកទេសកែច្នៃ ដើម្បីជំរុញទិន្នផលកសិកម្មរបស់ពួកគេឱ្យទទួលបានជោគជ័យ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាល ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារ ពិភពលោក បានបង្កើតគម្រោង CASDP ឡើង ដើម្បីសម្របសម្រួលដល់ការអភិវឌ្ឍន៍ខ្សែច្រវ៉ាក់តម្លៃពិពិធកម្ម កសិកម្មនៅក្នុងខេត្តគោលដៅនៃប្រទេសកម្ពុជា។

ទស្សនកិច្ចសិក្សានេះដែរ មានគោលដៅផ្លាស់ប្តូបទពិសោធន៍ ចែករំលែកទស្សនទាន ចំណេះដឹង និងការអនុវត្តជាក់ស្តែងក្នុងវិស័យសាកវប្បកម្មដោយបើកចំហរ និងចែករំលែកចំណេះធ្វើឱ្យគ្នាទៅវិញទៅមក។

លោក អ៊ុក សារឿន អនុប្រធាននាយកដ្ឋានសហគមន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF) និងលោក ហ៊ុន វុត្ថា ប្រធានសហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា បានធ្វើបទបង្ហាញ និងចែក រំលែកជាតុចូលរួមជាមួយក្រុមការងារគម្រោង CASDP ដែលបានផ្តោតលើការអនុវត្តល្អក្នុងវិស័យកសិកម្ម។

លើសពីនេះ សមាជិកសហគមន៍កសិកម្ម និងអ្នកចូលរួមចំនួន៤២ នាក់ បានចុះទៅមើលបន្លែសុវត្ថិ ភាពនៅក្នុងផ្ទះសំណាញ់ ពួកគាត់បានស្តាប់មតិអន្តរាគមន៍របស់មន្ត្រីនៃមន្ទីរកសិកម្ម (PDAFF) មកពីខេត្តកំពង់ ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, និងបាត់ដំបង និងសមាជិកចំនួន៣០នាក់ មកពី៦សហគមន៍ដូចជា សហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា, សហគមន៍កសិកម្មអាមត:, សហគមន៍កសិកម្មសាមគ្គីអមឡាំង, សហគមន៍បន្លែចម្រុះជាយក្រុងកំពង់ស្ពឺ, សហគមន៍

កសិកម្មទឹកហូតមានជ័យក្តីសង្ឃឹម, និងសហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង។

ការពិភាក្សាបានផ្តោតលើការជ្រើសរើសទីតាំងសង់ផ្ទះសំណាញ់ ដើម្បីឱ្យទឹករត់ស្មើល្អ, របៀបបង្ហូរទឹកកំឱ្យដក់ទឹក និងវិធីសង់ផ្ទះសំណាញ់, ការជ្រើសរើសពូជដំណាំវិលជុំជាលក្ខណៈគ្រួសារ ដើម្បីកាត់បន្ថយបញ្ហាសត្វល្អិត និងជំងឺឆ្លង ការត្រួតពិនិត្យដំណាំឱ្យបានជិតដល់ និងប្រើថ្នាំសម្លាប់សត្វល្អិតនៅពេលណាចាំបាច់, ការអនុវត្តតាមការណែនាំរបស់អ្នកជំនាញ, សម្អាតដីឱ្យបានស្អាតបន្ទាប់ពីប្រមូលផលរួច, ការដាំដុះ, ការធ្វើទីផ្សារ និងការបង្កើតបណ្តាញទីផ្សារលក់។ បទបង្ហាញនេះអនុញ្ញាតឱ្យអ្នកចូលរួមអាចកំណត់អត្តសញ្ញាណសត្វល្អិត និងជំងឺបន្លែ ដែលជាវិធានការមានសុវត្ថិភាពក្នុងការគ្រប់គ្រងប្រកបដោយនិរន្តរភាព។

ការរៀបចំឱ្យមានទស្សនកិច្ចសិក្សាសម្រាប់សមាជិកនៃសហគមន៍កសិកម្មទាំង៥ ទៅកាន់សហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា ខេត្តបាត់ដំបង ដែលជាតំបន់ផ្សេងពីតំបន់របស់ខ្លួន អនុញ្ញាតឱ្យអ្នកចូលរួមរៀនសូត្រដកពីបទពិសោធន៍ពីគ្នាទៅវិញទៅមក។ កម្មវិធីនេះដែរ សមាជិកសហគមន៍កសិកម្មទាំងអស់មានឱកាសចែករំលែកពីការអនុវត្តកសិកម្មល្អ ចែករំលែករឿងរ៉ាវជោគជ័យទៅវិញទៅមក និងទទួលធាតុចូលថ្មីពីកម្មវិធីនេះដែរ។

ជាលទ្ធផល ក្នុងអំឡុងពេលទស្សនកិច្ចសិក្សា សមាជិកសហគមន៍កសិកម្មទទួលបានគំនិតថ្មីៗសម្រាប់កែលម្អការអនុវត្តកសិកម្មរបស់ពួកគេ និងការពង្រឹងចំណេះដឹងផ្នែកសេដ្ឋកិច្ចគ្រួសារ និងសហគមន៍ដែលនឹងលើកកម្ពស់ផលិតកម្ម និងការផ្គត់ផ្គង់ទៅកាន់ទីផ្សារនាពេលអនាគត។





Photo: MAFF 2023

## អត្ថប្រយោជន៍នៃការប្រើប្រាស់ជញ្ជីងយន្តក្នុងវិស័យកសិកម្ម - ផលិតកម្មដំឡូងមី

កង្វះធាតុចូលកសិកម្មនៅតែជាបញ្ហាប្រឈមក្នុងផលិតកម្មដំឡូងមី។ នេះជាបញ្ហាប្រឈមថ្មីសម្រាប់ផលិតកម្មកសិកម្មរបស់ប្រទេស ប្រការនេះទាមទាឱ្យមានប្រព័ន្ធផលិតកម្មប្រកបដោយភាពច្នៃប្រឌិត គួរត្រូវបានដាក់ឱ្យដំណើការនៅកម្រិតផលិតកម្មកសិកម្មខ្នាតតូច។

ជញ្ជីងថ្លឹងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិត និងប្រតិបត្តិការកសិកម្ម ព្រោះវាអាចជួយសម្រួលដល់ដំណើរការគ្រប់គ្រងការប្រមូលផល។ គម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយធនាគារពិភពលោក (WB) បានគាំទ្រដល់សហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ ខេត្តព្រះវិហារ ដោយដំឡើងជញ្ជីងយន្តថ្លឹងដំឡូងមី និងប្រព័ន្ធជញ្ជីងថ្លឹង ឆ្លើយតាមតម្រូវការរបស់សហគមន៍កសិកម្ម។

ទំហំកសិដ្ឋានអាចមានផលប៉ះពាល់លើប្រសិទ្ធភាព និងប្រាក់ចំណេញយ៉ាងច្រើន វាអាស្រ័យបច្ចេកវិទ្យាឬសម្ភារដែលសហគមន៍កំពុងប្រើប្រាស់។ រាប់ចាប់ពីការតាមដានទិន្នផលកសិកម្មរហូតដល់ការគ្រប់គ្រង និងប្រមូលផលកសិកម្ម, សហគ្រាស និងសហគមន៍កសិកម្មភាគច្រើនពឹងផ្អែកលើដំណោះស្រាយថ្លឹងទម្ងន់ ដើម្បីជានាសុក្រិត

ភាពក្នុងដំណើរការថ្លឹងទម្ងន់ផលិតផលកសិកម្មប្រចាំថ្ងៃរបស់ពួកគេ។ កិច្ចអន្តរាគមន៍របស់ គម្រោងបានជួយកសិករដំឡូងមី បង្កើនប្រសិទ្ធភាពក្នុងគ្រប់គ្រងការប្រមូលផល និងជួយកាត់បន្ថយ ការចំណាយលើថ្លៃដើម។

អ្នកជំនាញផ្នែកកសិឧស្សាហកម្ម បានណែនាំសហគមន៍កសិកម្មគួរមានប្រព័ន្ធថ្លឹងទម្ងន់ត្រឹមត្រូវ និងមានប្រសិទ្ធភាពសម្រាប់ការអនុវត្តកសិកម្មរបស់ពួកគេ។ ដោយសារតែជញ្ជីងថ្លឹងមានភាពរហ័សរហួន ត្រឹមត្រូវ និងអាចទុកចិត្តបានរាល់ពេល ដែលអាចកាត់បន្ថយការដឹកទំនិញកសិផលិតផលលើសទម្ងន់។





Photo: MAFF 2023

## មន្ត្រីបង្គោលចំនួន១៥ រូប មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF) ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ឌីជីថល និងប្រព័ន្ធទំនាក់ទំនងសង្គម

កន្លងមកភាគច្រើននៃព័ត៌មានគម្រោងមានទម្រង់ជារបាយការណ៍នៅលើក្រដាស ហើយការចុះឈ្មោះប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងសង្គមអមដោយរូបភាពមានគុណភាព នៅមិនទាន់ត្រូវបានអនុវត្តឱ្យបានទូលំទូលាយនៅឡើយ ជាពិសេសលើបណ្តាញសង្គម Facebook។ ថ្មីៗនេះ គម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា (CASDP) បានរិះរកមធ្យោបាយគាំទ្រមន្ត្រីបង្គោលរបស់គម្រោងក្រោមឱវាទមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF) ដោយចាត់ទុកថាការបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ សង្គមពិតជាមានសារសំខាន់សម្រាប់ PDAFF ដែលជានិច្ចកាលនៅមិនទាន់បានធ្វើទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅខេត្តកំពង់ចាម – នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយមានការគាំទ្រពីគម្រោង CASDP បានបើកវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធឌីជីថល និងប្រព័ន្ធផ្សព្វ ផ្សាយសង្គមសម្រាប់មន្ត្រីបង្គោលគម្រោង CASDP ចំនួន១៥ រូប មកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (PDAFF) មកពីខេត្តគោលដៅទាំង១៣ របស់គម្រោង។

ក្នុងវគ្គបណ្តុះបណ្តាលរយៈពេល១ថ្ងៃ ក្រុមការងារគម្រោងបានពិភាក្សាពីយន្តការពង្រឹងការផ្សព្វផ្សាយ និងទំនាក់ទំនងគម្រោងក្នុងចំណោមមន្ត្រីនៃមន្ទីរកសិកម្ម (PDAFF) លើជំនាញប្រើប្រាស់ប្រព័ន្ធឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយសង្គម ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) និងការសរសេរបទពិព័ណនាស្តីពីភាពជោគជ័យរបស់អ្នកទទួលផលគម្រោង ដើម្បីផ្សព្វផ្សាយតាមប្រព័ន្ធទំនាក់ទំនងសង្គម និងរួមចំណែកចែករំលែកលទ្ធផល គម្រោងឱ្យកាន់តែទូលំទូលាយ។

បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះទៅ មន្ត្រីបង្គោលមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម តាមរយៈទូរស័ព្ទដៃកាន់តែទូលំទូលាយ។ មន្ត្រីនៃមន្ទីរកសិកម្មខេត្តភាគច្រើនមានប្រព័ន្ធផ្សព្វផ្សាយសង្គម និងយកចំណេះដឹងទទួលបានពីវគ្គបណ្តុះបណ្តាលយកទៅប្រើប្រាស់តាមវិធីសាមញ្ញ និងមានអន្តរកម្ម ជាហេតុនាំឱ្យមន្ត្រីបង្គោល អាចទាញយកអត្ថប្រយោជន៍ពេញលេញពីប្រព័ន្ធផ្សព្វផ្សាយសង្គម ធ្វើឱ្យមហាជនចូលរួមគាំទ្រកាន់តែច្រើនក្នុងសកម្មភាពកសិកម្ម។

# ម៉ាស៊ីនគោយន្តជួយកសិករសន្សំសំចៃពេលវេលា ថវិកា និងថាមពល






_លោក ពឿង ទ្រីដា (រូបកណ្តាល) ប្រធានមន្ទីរក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. Photo: MAFF/2023

ការកែលម្អការអនុវត្តគ្រប់គ្រងដី ដោយប្រើប្រាស់បច្ចេកទេសរៀបចំដី, ទឹក និងការកែលម្អធាតុចូល កសិកម្ម អាចធ្វើឲ្យផលិតកម្មកសិកម្មបានប្រសើរឡើង។ កង្វះធាតុចូលកសិកម្មដូចជា (ម៉ាស៊ីនគោយន្ត ត្រាក់ទ័រ) នៅតែជាបញ្ហាប្រឈមនៅឡើយសម្រាប់ការអនុវត្តខ្សែសង្វាក់តម្លៃផលិតកម្មដំឡូងមី។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយធនាគារពិភពលោក តាមរយៈគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP) បានដាក់បញ្ចូលកម្មវិធីឥណទាន ៤0% ជាទុនវិនិយោគបំពេញបន្ថែមទៅក្នុងផែនការអាជីវកម្មរបស់សហគមន៍កសិកម្ម ដើម្បីគាំទ្រដល់ការកែលម្អខ្សែប្រវ៉ាក់តម្លៃផលិតកម្មដំឡូងមីសម្រាប់ផ្គត់ផ្គង់ទីផ្សារ។ ក្នុងចំណោមសហគមន៍កសិកម្មដែលបានដាក់ស្នើសុំកិច្ចអន្តរាគមន៍ពីគម្រោង CASDP សហគមន៍កសិកម្មភ្នំពេជ្របូរី និងសហគមន៍លើកកម្ពស់កសិករក្នុងខេត្តព្រះវិហារបានបញ្ចប់ដំណើរការលទ្ធកម្មរបស់ខ្លួន ដើម្បីទិញម៉ាស៊ីនគោយន្តយកមកប្រើឱ្យទាន់រដូវប្រមូលផល។

សមាជិកសហគមន៍កសិកម្មភ្នំពេជ្របូរីទទួលបានម៉ាស៊ីនគោយន្តចំនួន៣០គ្រឿង ក្នុងនោះគោយន្ត ២០ គ្រឿងត្រូវបានផ្តល់ជូននៅខែសីហា និង១០ គ្រឿងផ្តល់ជូននៅខែធ្នូ ឆ្នាំ២០២៣។ ក្នុងឆ្នាំដដែលនេះដែរ សមាជិកសហគមន៍លើកកម្ពស់កសិករ បានទទួលគោយន្តចំនួន១៤ គ្រឿងនៅខែកញ្ញា។ លោក ពឿង ទ្រីដា ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ បានអញ្ជើញជាសាក្សីក្នុងពិធីប្រគល់គោយន្តនៅការិយាល័យសហគមន៍ទាំងពីរខាងលើ។

នាឱកាសនោះ តំណាងក្រុមហ៊ុនគូប៊ូតា បានបង្រៀនកសិករដំឡូងមី ពីរបៀបដំណើរការ និងថែទាំម៉ាស៊ីនគោយន្ត។ ចំណុចល្អរបស់ម៉ាស៊ីនគោយន្ត ដែលសមាជិកសហគមន៍ភាគច្រើននិយាយថា វាអាចប្រើប្រាស់សម្រាប់ការដាំដុះ, បូមទឹក, បោកស្រូវ, ដឹកជញ្ជូនកសិកផល, និងភ្ជួររាស់បានទាំងអស់។ ពួកគេក៏បាននិយាយថា ម៉ាស៊ីនគោយន្តនេះនឹងជួយសន្សំសំចៃពេលវេលា និងថាមពល ដោយសារវាដំណើរការលឿនជាងការគោដល់ទៅពីរដងឯណោះ។ លើសពីនេះ ម៉ាស៊ីនគោយន្តក៏ត្រូវបានគេប្រើសម្រាប់ព្រួសគ្រាប់ពូជ និងប្រើជីក្នុងពេលតែមួយ។ ម៉ាស៊ីននេះនឹងជួយឱ្យកសិករទទួលបានសមាមាត្រជីត្រឹមត្រូវទៅតាមប្រភព និងប្រភេទដំណាំផ្សេងៗ។

# អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា MEF-PIU/CASDP បើកវគ្គបណ្តុះបណ្តាលស្តីពី "យុទ្ធសាស្ត្ររៀបចំហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម"






_**PFI Staff and Lecture,** at the ACLEDA AIB Training Centre. Photo: MEF/2023

កាលពីថ្ងៃទី១២ ដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ នៅវិទ្យាស្ថានពានិជ្ជសាស្ត្រអេស៊ីលេដា ( ACLEDA AIB Training Centre ) អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( MEF-PIU/ CASDP ) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "យុទ្ធសាស្ត្ររៀបចំហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្ម" ដល់គ្រឹះស្ថានហិរញ្ញវត្ថុដែលចូលរួមអនុវត្តគម្រោង និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតផ្តោតលើវិស័យកសិកម្ម។ វគ្គបណ្តុះបណ្តាលនេះ បានប្រព្រឹត្តិទៅក្រោមកិច្ចសម្របសម្រួលដោយមហាវិទ្យាល័យហ្វ្រេងហ្វឹតសម្រាប់ជំនាញហិរញ្ញវត្ថុ និងគ្រប់គ្រង ( Frankfurt School of Finance & Management មានមូលដ្ឋាននៅប្រទេសអាល្លឺម៉ង់ និងវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលេដា ( AIB ) ដែលជាដៃគូរបស់គម្រោង និងមានបទពិសោធន៍ក្នុងការបណ្តុះបណ្តាលលើផ្នែកហិរញ្ញប្បទានខ្សែច្រវាក់តម្លៃ។

វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រឹះស្ថានហិរញ្ញវត្ថុ ដែលចូលរួមអនុវត្តគម្រោងក៏ដូចជាគ្រឹះស្ថានហិរញ្ញវត្ថុពាក់ព័ន្ធ ដែលធ្វើការពាក់ព័ន្ធនិងវិស័យកសិកម្មក្នុងការផ្តល់ ហិរញ្ញប្បទានដែលមានលក្ខណៈខ្សែច្រវាក់តម្លៃកាន់តែមានភាពទូលំទូលាយ និងប្រសិទ្ធភាព។ វគ្គបណ្តុះបណ្តាលនេះចែកចេញជាពីរកម្រិត៖ កម្រិតទី១ សម្រាប់មន្ត្រីជាន់ខ្ពស់របស់គ្រឹះស្ថានហិរញ្ញវត្ថុ ដោយផ្តោតលើយុទ្ធសាស្ត្ររៀបចំហិរញ្ញប្បទានខ្សែច្រវ៉ាក់តម្លៃ និងកម្រិតទី២ សម្រាប់មន្ត្រីឥណទាន ផ្តោតលើការផ្តល់ហិរញ្ញប្បទានខ្សែច្រវ៉ាក់តម្លៃ ។

សមភាពចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះរួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ធនាគារប្រៃសណីយ៍កម្ពុជា ក.ង, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេអឹមខេ ភីអិលស៊ី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន ម.ក, ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា, ធនាគារ ABA, ធនាគារខេប៊ីប្រាសាក់ ម.ក និង គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ អិលអូអិលស៊ី( កម្ពុជា ) ភីអិលស៊ី។

វគ្គបណ្តុះបណ្តាលបានបញ្ចប់ដោយជោគជ័យ ដោយបានទទួលមតិត្រឡប់ពីអ្នកចូលរួមស្តីពីការប្រើប្រាស់ចំណេះដឹងដែលបានចែករំលែកនៅក្នុងអង្គសិក្ខាសាលា ដែលជាការបោះជំហានយ៉ាងសំខាន់ពីការបណ្តុះបណ្តាលនៅក្នុងថ្នាក់រៀនឆ្ពោះទៅរកការអនុវត្តជាក់ស្តែង ដោយផលតបមកវិញនៃចំណេះដឹងនេះមានតម្លៃធំធេងណាស់។ ម្យ៉ាងវិញទៀតអ្នកចូលរួមភាគច្រើនបានផ្តោតអារម្មណ៍លើប្រតិបត្តិការ ដែលជាចាំបាច់ត្រូវមានការគាំទ្រជាលក្ខណៈ

បុគ្គល តាមរយៈកិច្ចប្រជុំនៅកម្រិតប្រតិបត្តិការ ដើម្បីណែនាំអំពីគំនិតផ្តួចផ្តើមថ្មីៗនៅស្ថាប័នហិរញ្ញវត្ថុរបស់ខ្លួន។

សិក្ខាកាមបានស្នើសម្រាប់វគ្គបំពាក់បំប៉ន ដែលមានបទបង្ហាញរយៈពេល១ម៉ោងសម្រាប់ស្ថានប័នហិរញ្ញប្បទានដែលចូលរួមអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា ពិចារណាដាក់បញ្ចូលចំណេះដឹងមូលដ្ឋានចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលក្រោយៗ។ ចំណែកឯលទ្ធរំពឹងទុកវិញគួររៀបចំចងក្រងឱ្យបានច្បាស់លាស់ស្របគ្នាទៅនឹងសូចនាករសំខាន់ៗ នឹងត្រូវពិនិត្យឡើងវិញសម្រាប់វគ្គបណ្តុះបណ្តាលក្រោយៗ។



*Photo: MEF 2023*

## ទុន៤០% ជួយសមាជិកសហគមន៍ព្រះរំកិលពង្រីកអាជីវកម្មចិញ្ចឹមជ្រូក និងបង្កើនមុខរបរពីរបន្ថែម

លោក អ៊ូ សំឃិត រស់នៅភូមិ ក្រោម ឃុំ ព្រះរំកិល ស្រុក បូរីអូស្វាយសែនជ័យ ខេត្ត ស្ទឹងត្រែង មានអាយុ៣៥ឆ្នាំ ទទួលបានការគាំទ្រពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា នូវឥណទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ៤០% សរុបសម្រាប់ចិញ្ចឹមជ្រូក តាមរយៈសមាជិកភាពនៃសហគមន៍កសិកម្មព្រះរំកិល ។

មុនពេលទទួលបានឥណទាន លោកបានប្រកបរបរដាំដំឡូងមី និងចិញ្ចឹមជ្រូកចំនួន៣ក្បាល ដែលលោកអាចសន្សំប្រាក់បានតិចតួចប៉ុណ្ណោះក្នុងអំឡុងពេលបិទខ្ទប់ ដោយសារការរីករាលដាលនៃមេរោគកូវីដ១៩។ នៅពេលចាប់ផ្តើមអាជីវកម្មចិញ្ចឹមជ្រូក គាត់បានប្រឈមមុខនឹងបញ្ហាខ្វះខាតទុនបង្វិលទិញកូនជ្រូកមកចិញ្ចឹម។ ជាងនេះទៅទៀត អត្រាស្លាប់ និងកូនជ្រូកក៏មានជំងឺច្រើន ដោយសារគាត់ខ្វះជំនាញក្នុងវិស័យនេះ។

អាស្រ័យហេតុនេះ គម្រោងពិពិធកម្មកសិកម្មកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមកិច្ចសហការជាមួយធនាគារពិភពលោក បានពិភាក្សារកដំណោះស្រាយជាមួយអ្នកជំនាញបសុសត្វមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង។ តាមការណែនាំរបស់ PDAFF ដែលមានភាពប៉ិនប្រសប់ផ្នែកវិទ្យាសាស្ត្រសហគ្រាសចិញ្ចឹមជ្រូក លោក អ៊ូ សំឃីត ក៏មានឱកាសបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ចិញ្ចឹមជ្រូកជាមួយសមាជិកផ្សេងទៀត នៅការិយាល័យសហគមន៍កសិកម្មព្រះរំកិលក្នុងឆ្នាំ២០២៣។ សមាជិកទាំងអស់ទទួលបានការណែនាំ និងបានចុះទៅមើលកសិដ្ឋានក្បែរៗនៅក្នុងខេត្តផងដែរ។



_លោក អ៊ូ សំឃិត, កសិករចិញ្ចឹមជ្រូកយកសាច់ និងយកកូន, និងជាសមាជិកសហគមន៍សហគមន៍កសិកម្មព្រះរំកិល Photo: Chuon/2023

*ខ្ញុំចាប់ផ្តើមចិញ្ចឹមជ្រូកនៅឆ្នាំ២០១៥ មកដល់ពេលនេះមានរយៈពេល៨ ឆ្នាំហើយ។ ខ្ញុំជួបបញ្ហាច្រើនក្នុងការចិញ្ចឹមជ្រូកនៅសម័យកូវីដ១៩ ដោយសារការបិទខ្ទប់ ចំណែកការដាំដំឡូងមីក៏ជួបបញ្ហាដូចគ្នា ខ្ញុំក៏ងាកមកចិញ្ចឹមជ្រូកវិញ។*

*មុនពេលអន្តរាគមន៍របស់គម្រោង ខ្ញុំជួបការលំបាក់ខ្លះក្នុងការចិញ្ចឹមជ្រូក ដោយសារខ្ញុំមិនមានចំណេះដឹងពីជំងឺជ្រូកថាវាឈឺបណ្តាលមកពីមូលហេតុអ្វី យើងអត់ស្គាល់ថ្នាំយកមកប្រើឱ្យត្រូវនឹងប្រភេទជំងឺ។*

ដោយមានការគាំទ្រពីគម្រោង CASDP នូវឥណទាន៤០% យកមកពង្រីកអាជីវកម្មចិញ្ចឹមជ្រូក គួបផ្សំជាមួយការចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយគម្រោងស្តីពីការចិញ្ចឹមជ្រូក ការថែទាំកូនជ្រូក និងការឱ្យចំណីជ្រូក ធ្វើឱ្យលោកសំឃិត បានយល់ពីរបៀបសង្កេតមើលថែទាំជ្រូកបានយ៉ាងល្អក្រោយពីបញ្ចប់វគ្គបណ្តាលបណ្តាល។

កម្មវិធីបណ្តុះបណ្តាលបានផ្តោតជាពិសេសទៅលើការបញ្ចុះព្រូនឱ្យបានទៀងទាត់ ការចាក់វ៉ាក់សាំងទាន់ពេលវេលា និងការសម្អាតទ្រុងអោយបានត្រឹមត្រូវ និងបាញ់ទឹកដើម្បីកាត់បន្ថយការស្លាប់របស់ជ្រូកនៅក្នុងកសិដ្ឋាន។ ក្រោយពីទទួលបានការណែនាំស្តីពីការអនុវត្តគ្រប់គ្រងចិញ្ចឹមជ្រូកដែលមន្ទីរជំនាញបានផ្តល់អោយ លោក សំឃិត ទទួលបានផលប្រយោជន៍ច្រើន ដោយគាត់អាចលក់ជ្រូកយកសាច់ចំនួន៣០ក្បាល និងកូនជ្រូកពូជចំនួន៥០ ក្បាល នៅក្នុងឆ្នាំ២០២៣ ដោយទុកកូនជ្រូកដែលនៅសល់សម្រាប់ធ្វើពូជបន្ត។ គាត់បានលក់ជ្រូកឈ្មោល និងចាស់សម្រាប់យកសាច់។ ចំណែកទីផ្សារជ្រូកវិញ លោក សំឃិត បានលក់អ្នកភូមិ និងអាជីវករជ្រូកយកសាច់មកពីខេត្ត។

បច្ចុប្បន្នលោក សំឃឹត បានផ្លាស់ប្តូរជីវភាពច្រើនបន្ទាប់ពីជ្រើសរើសយករបរចិញ្ចឹមជ្រូក។ ឥឡូវនេះ គាត់មានដីកសិដ្ឋានចិញ្ចឹមជ្រូកយ៉ាងទូលំទូលាយ និងមានកន្លែងសត្តឃាតផ្ទាល់ខ្លួន។ ចំណូលពីការលក់ជ្រូកបានជួយផ្គត់ផ្គង់គ្រួសារ ហើយគាត់បានប្រើប្រាស់ថវិកាដែលនៅសល់យកទៅពង្រីកមុខរបរបន្ថែម ដូចជាដាំស្វាយចន្ទី និងដំឡូងមី ក្នុងនោះដំណាំស្វាយចន្ទីប្រហែល១០ ហិកតា និងដំឡូងមីប្រហែល៣ ទៅ៤ ហិកតា។

លោក សំឃិត កាន់តែមានកេរ្តិ៍ឈ្មោះជាអ្នកចិញ្ចឹមជ្រូកមានគុណភាពល្អ ហើយមានតម្រូវការច្រើនរហូតមានឈ្មួញមករកទិញជាហូរហែរ។ លោកសម្រេចលក់ជ្រូកឲ្យអ្នកទិញផ្ទាល់ ជៀសវាងលក់ឱ្យឈ្មួញកណ្តាលដែលតែងតែឲ្យតម្លៃទាបជាងទីផ្សារ។ ក្រៅពីនេះ អាជីវករនៅក្រុងស្ទឹងត្រែងក៏បានមកទាក់ទងទិញជ្រូកពីគាត់យកទៅលក់បន្ត។ លោក សំឃិត ជាអ្នកប្រកបរបរចិញ្ចឹមជ្រូក ដោយគាត់រីករាយក្នុងការចែករំលែក បទពិសោធន៍ជោគជ័យរបស់គាត់ទៅដល់កសិករជាច្រើននៅក្នុងសហគមន៍ ហើយមានកសិករចន្លោះពី១៥ ទៅ ២០ នាក់បានចាប់ផ្តើមចិញ្ចឹមជ្រូកដូចជាគាត់ដែរ។ ពេលនេះសមាជិកសហគមន៍សប្បាយចិត្ត និងពេញចិត្តជាមួយការសម្រេចចិត្តរបស់ពួកគេ ហើយថាគ្មានបញ្ហាអ្វីទៀតទេក្នុងការចិញ្ចឹមជ្រូកដែលជាមុខរបរចិញ្ចឹមជីវិត។

*ខ្ញុំសប្បាយចិត្តជាមួយនឹងអាជីវកម្មចិញ្ចឹមជ្រូក ។ ខ្ញុំសូមអរគុណដល់គម្រោង CASDP ដែលផ្តល់ជំនួយ ៤០% យកមកចិញ្ចឹមជ្រូក ដែលធ្វើអោយខ្ញុំអាចពង្រីកអាជីវកម្មបានពីរបន្ថែមទៀត" ។*

ស្របពេលជាមួយគ្នានេះដែរ លោក សំឃិត បានជំរុញឲ្យស្ត្រីក្នុងភូមិពិចារណាងាកមកចិញ្ចឹមជ្រូកដូចលោកដែរ ព្រោះវាអាចរកប្រាក់ចិញ្ចឹមគ្រួសារបាន ។ ជាចុងក្រោយ លោកបានស្នើដល់គម្រោង CASDP ផ្តល់បទពិសោធន៍បន្ថែមដល់កសិករដូចរូបលោក និងជួយស្វែងរកទីផ្សារដែលមានតម្លៃប្រសើរជាងមុន ។




Photo: MAFF 2023



**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
គម្រោងពិពិធកម្មកសិកម្មកម្ពុជា (**CASDP**)
អាសយដ្ឋាន៖ #២០០,មហាវិថីព្រះនរោត្តម,សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, ភ្នំពេញ
**Website:** https://casdp.maff.gov.kh/
**Facebook:** Casdpcambodia

THE WORLD BANK
IBRD • IDA | WORLD BANK GROUP